ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ឥណ្ឌូនេស៊ី លើកទី៤
## ទីក្រុងហ្សាការតា ថ្ងៃទី០៣-០៤ ខែធ្នូ ឆ្នាំ២០១៨

*****

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូអញ្ជើញទៅចូលរួម និងធ្វើជាសហប្រធានកិច្ចប្រជុំគណៈកម្មការចម្រុះនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឥណ្ឌូនេស៊ី លើកទី៤ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។

មុនពេលធ្វើជាសហប្រធានកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី លើកទី៤ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងលោកជំទាវ រ៉េតណូ អិល.ភី ម៉ារស៊ូឌី បានជួបប្រជុំទ្វេភាគី ដែលក្នុងនោះ រដ្ឋមន្ត្រីការបរទេសទាំងពីរ បានចែករំលែកគ្នាទៅវិញទៅមកនូវសភាពការណ៍ស្តីពីនយោបាយ និងសេដ្ឋកិច្ចសង្គមបច្ចុប្បន្ននៃប្រទេសរបស់ខ្លួន និងទស្សនៈស្តីពីបញ្ហាតំបន់។

ក្នុងអំឡុងកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី លើកទី៤ ភាគីទាំងពីរបានបង្ហាញទស្សនៈរួមគ្នាថា ខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងឥណ្ឌូនេស៊ី នៅឆ្នាំ២០១៩ នឹងក្លាយទៅជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងប្រទេសទាំងពីរ។ ភាគីទាំងពីរបានស្វាគមន៍គម្រោងរៀបចំសកម្មភាពរួមគ្នាជាច្រើន ដើម្បីប្រារព្ធព្រឹត្តិការណ៍ដ៏ឧឡារិកនេះ។

ភាគីទាំងពីរ បានពិភាក្សាយ៉ាងទូលំទូលាយ និងស៊ីជម្រៅ លើការអភិវឌ្ឍនៃទំនាក់ទំនងទ្វេភាគី និងវិធានការក្នុងការពង្រីក និងធ្វើឲ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការជាច្រើន ដូចជា ការពារជាតិនិងសន្តិសុខ ពាណិជ្ជកម្មនិងវិនិយោគ កសិកម្ម ការតភ្ជាប់ផ្លូវអាកាស ឧស្សាហកម្ម ថាមពល វប្បធម៌ ទេសចរណ៍ អប់រំ ព័ត៌មាន ការដឹកជញ្ជូន និងសុខាភិបាល។

រដ្ឋមន្ត្រីទាំងពីរបានឯកភាពគ្នាលើកទឹកចិត្តឲ្យបញ្ចប់នីតិវិធីផ្ទៃក្នុង ដែលចាំបាច់សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ ដែលបានចុះហត្ថលេខានៅ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855) 23 214 441, 216 122
ទូរសារ: (855) 23 216 144, 216 141
អ៊ីមែល: mfaic@mfa.gov.kh

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ និងបានស្វាគមន៍គំនិតផ្តួចផ្តើមបង្កើនកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធរវាងស្ថាប័នការពារជាតិពាក់ព័ន្ធនៃប្រទេសទាំងពីរ។

ខណៈកំពុងកត់សំគាល់ពីការរីកចម្រើននៃទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ រដ្ឋមន្ត្រីទាំងពីរបានឯកភាពឲ្យមានការពិភាក្សាពីលទ្ធភាពក្នុងការធ្វើវិសោធនកម្មនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងកម្ពុជា និងឥណ្ឌូនេស៊ី ដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩៧ ដើម្បីរួមបញ្ចូលការវិវត្តថ្មីៗនៃពាណិជ្ជកម្មនៅក្នុងប្រទេសទាំងពីរ។

កិច្ចប្រជុំបានឯកភាពលើកទឹកចិត្តការវិនិយោគលើឧស្សាហកម្មថ្នាំពេទ្យ ស៊ីម៉ង់ ជីគីមី កៅស៊ូ អាហារកែច្នៃ និងឧស្សាហកម្មរថយន្ត។ រដ្ឋមន្ត្រីទាំងពីរ ក៏បានស្វាគមន៍ការកើនឡើងការវិនិយោគរបស់ឥណ្ឌូនេស៊ី នៅកម្ពុជាផងដែរ។ ដោយកត់សំគាល់ឃើញភាពវិជ្ជមាននេះ ភាគីឥណ្ឌូនេស៊ីឯកភាពបន្តលើកទឹកចិត្តអ្នកវិនិយោគ មកវិនិយោគនៅកម្ពុជាបន្ថែមទៀត។

កិច្ចប្រជុំបានឯកភាពគ្នាសម្រួលការធ្វើពាណិជ្ជកម្មបន្ថែមទៀតលើផលិតផលកសិកម្ម និងពន្លឿនកិច្ចពិភាក្សាលើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម។

កិច្ចប្រជុំបានជំរុញឲ្យមានការបង្កើនការតភ្ជាប់ផ្លូវអាកាស និងលើកទឹកចិត្តប្រតិបត្តិករអាកាសចរណ៍ឲ្យធ្វើប្រតិបត្តិការហោះហើរត្រង់រវាងប្រទេសទាំងពីរ។

ភាគីទាំងពីរបានលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធ ឲ្យពិនិត្យឡើងវិញលើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩៩ និងបានស្វាគមន៍គំនិតផ្តួចផ្តើមពង្រីកកិច្ចសហប្រតិបត្តិការរួមគ្នា ដើម្បីជំរុញទិដ្ឋភាពវប្បធម៌រួមរវាងកម្ពុជា និងឥណ្ឌូនេស៊ី។ លើសពីនេះ កិច្ចប្រជុំក៏បានលើកទឹកចិត្តឲ្យមានការបន្តសុពលភាពអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌ ដែលនឹងត្រូវអស់សុពលភាពនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩។

ភាគីកម្ពុជាបានថ្លែងអំណរគុណ ចំពោះការបន្តជួយរបស់ឥណ្ឌូនេស៊ីក្នុងការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅសិក្សានៅប្រទេសឥណ្ឌូនេស៊ី ហើយភាគីទាំងពីរបានស្វាគមន៍គំនិតផ្តួចផ្តើមនៃកិច្ចសហការរវាងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិរបស់កម្ពុជា និងមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលនៃក្រសួងការបរទេសឥណ្ឌូនេស៊ី។

ក្រៅពីនេះ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាតំបន់ និងសកល ដែលជាកង្វល់រួមក្នុងនោះក៏មានគំនិតផ្តួចផ្តើមឥណ្ឌូ-ប៉ាស៊ីហ្វិកផងដែរ។

ភាគីទាំងពីរ បានឯកភាពរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឥណ្ឌូនេស៊ី លើកទី៥ នៅឆ្នាំ២០២០ នៅកម្ពុជា។

នៅពេលបញ្ចប់កិច្ចប្រជុំគណៈកម្មការចម្រុះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីលើកទី៤ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងលោកជំទាវ រ៉េតណូ អិល.ភី ម៉ារស៊ូឌី បានចុះហត្ថលេខារួមគ្នាលើកំណត់ហេតុស្តីពីលទ្ធផលនៃកិច្ចប្រជុំ។

ថ្ងៃពុធ ទី១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨